ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២៨៤/១៣ - ម៉ឹង យ៉ា
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ម៉ឹង យ៉ា**

អាសយដ្ឋាន ៖ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ គ្មាន ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖ អវត្តមាន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សម្ព័ន្ធសហជីពកម្ពុជា**

- **សហជីពកម្ពុជានៃរោងចក្រកាត់ដេរ ម៉ឹង យ៉ា**

អាសយដ្ឋាន ៖ ផ្ទះលេខ ២៥ QEO ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦៦៧ ០៩៨ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

១- លោក សល់ គីមសាន មន្ត្រីសម្ព័ន្ធសហជីពកម្ពុជា

២- លោក ជុំ គៀភត្រា ប្រធានសហជីពកម្ពុជានៃរោងចក្រ ម៉ឹង យ៉ា

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- រោងចក្រត្រូវតែទទួលយកលោក ជុំ តឿកត្រា តួនាទីជាប្រធានសហជីព លោក ជន ណៃ ជាអនុប្រធានសហជីព លោក រ៉ុត នួន ជាលេខាធិការសហជីព ឱ្យចូលបំរើការងារដូចដើមវិញ និងបញ្ឈប់ការរើសអើងចំពោះសហជីព ។

២- រោងចក្រត្រូវរៀបចំឱ្យមានរដ្ឋបាលនៅក្នុងរោងចក្រ ។

៣- សុំពេលកម្មករឈឺមកវិញមានសំបុត្រពេទ្យ សូមរក្សាអត្ថប្រយោជន៍នៅដដែល ។

៤- សុំរោងចក្រកាត់លុយរង្វាន់ទៀងទាត់តាមសមាមាត្រ ។

៥- សុំឱ្យរោងចក្ររក្សាលុយរង្វាន់ទៀងទាត់ នៅពេលដាក់ច្បាប់ពិសេស ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១១) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ០៧៣ កប/កណ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពកម្ពុជា លេខ ០៩៤/១៣ សសក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការស្នើសុំ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល អន្តរាគមន៍ករណីរោងចក្រ ម៉ឹង យ៉ា ហ្គាមេន មិនគោរពច្បាប់ស្តីពីការងារ និងរើសអើងសហជីព ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ មន្ទីរការងារ

និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកណ្ដាល បានធ្វើការផ្សះផ្សាវិវាទការងាររួមទាំង ០៥ ចំណុច ដោយមិនទទួលការសះជានឹងគ្នាទេ។ ចំណុចមិនសះជាចំនួន ០៥ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមលេខ ០៧៣ កប/កណ ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើងនៅថ្ងៃទី០២ ខែមករា ឆ្នាំ ២០១៤។ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ ២០១៤ វេលាម៉ោង ៩ និង ៤៥ នាទី ព្រឹក មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺលោក ប៉ែន សាវ៉ាត បានធ្វើដំណើរទៅដល់រោងចក្រដើម្បីប្រគល់លិខិតអញ្ជើញទៅភាគីនិយោជកឱ្យចូលរួមសវនាការ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ជាកំហិត។ សន្តិសុខនៃក្រុមហ៊ុន ម៉ឹង យ៉ា មិនអាចចុះហត្ថលេខាទទួល លើលិខិតអញ្ជើញនេះទេ ប៉ុន្តែយល់ព្រមទទួលយកលិខិតអញ្ជើញនេះ ទុកជូននាយកក្រុមហ៊ុន។ ភាគីកម្មករនិយោជិត មានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ រីឯ ភាគីនិយោជកមិនបានចូលរួមសវនាការអាជ្ញាកណ្ដាល តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ។

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបានសម្រេចដកចំណុចវិវាទចំនួន ៤ គឺចំណុចវិវាទទី២, ទី៣, ទី៤ និងទី៥។ ហេតុនេះ ចំណុចវិវាទចំនួន ០១ ដែលនៅសល់ ត្រូវស្ថិតក្រោមដំណើរការអាជ្ញាកណ្ដាល គឺចំណុចវិវាទទី១។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- បង្កាន់ដៃទទួលសំណុំរឿងរបស់នាយកដ្ឋានវិវាទការងារ បានទទួលពីសហជីពកម្ពុជា (ម៉ឹង យ៉ា) សុំចុះបញ្ជិកាសហជីព ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣។

២- លិខិតលេខ ០៩៤/១៣ សសក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូនប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកណ្ដាល សំណើសុំអន្តរាគមន៍ករណីរោងចក្រ ម៉ឹង យ៉ា មិនគោរពច្បាប់ស្ដីពីការងារ និងរើសអើងសហជីព។

៣- លិខិតលេខ ១១៥/១៣ សករកមយហ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់សហជីពកម្ពុជា រោងចក្រ ម៉ឹង យ៉ា ហ្គាមេន គោរពជូន រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សំណើសុំចុះបញ្ជិកាសហជីពកម្ពុជានៃរោងចក្រកាត់ដេរ ម៉ឹង យ៉ា ហ្គាមេន។

៤- កំណត់ហេតុ ស្តីពីការបង្កើតសហជីពកម្ពុជានៃរោងចក្រកាត់ដេរ មុឹង យ៉ា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១៣។

៥- បញ្ជីរាយនាមថ្នាក់ដឹកនាំសហជីពកម្ពុជានៃរោងចក្រកាត់ដេរ មុឹង យ៉ា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១៣។

៦- លិខិតលេខ ០៨៦/១៣ សសក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូន នាយករោងចក្រ មុឹង យ៉ា ជូនដំណឹងស្តីពីថ្នាក់ដឹកនាំអាណត្តទី១ សហជីពកម្ពុជាចំនួន ៣ រូប។

៧- សាលកប័ត្រផ្ញើសេវា EMS ក្នុងប្រទេស ដែលផ្ញើពីឈ្មោះ យ៉ាង សុភ័ណ្ឌ ជូនទៅ នាយកក្រុមហ៊ុន មុឹង យ៉ា ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន មុឹង យ៉ា លេខ ០៧៣ កប/កណ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន មុឹង យ៉ា ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០០៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០០៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- តាមរយៈកំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ ក្រុមហ៊ុន មុឹង យ៉ា ហ្គាមេន គឺជាក្រុមហ៊ុនមានសកម្មភាពចម្បង ក្នុងការកាត់ដេរសម្លៀកបំពាក់ ដែលមានជួលកម្មករនិយោជិត ចំនួនប្រមាណជាង ២០០ នាក់។
- កម្មករ ជុំ តឿភត្រា ជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិត ដែលចូលរួមរួមមាន ៖ លោក សល់ គឹមសាន ជាមន្ត្រីសម្ព័ន្ធសហជីពកម្ពុជា និងកម្មករ ជុំ តឿភត្រា។

ចំណុចវិវាទ ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយក លោក ជុំ គៀវភត្រា តួនាទីជាប្រធានសហជីព លោក ជន ណៃ ជាអនុប្រធានសហជីព លោក វុីត នួន ជាលេខាធិការសហជីព ឱ្យចូលបម្រើការងារដូចដើមវិញ និងបញ្ឈប់ការរើសអើងចំពោះសហជីព

- នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ស្នើសុំឱ្យនិយោជកទទួលយកកម្មករ ជុំ គៀវភត្រា ឱ្យចូលបម្រើការងារដូចដើមវិញ និងបញ្ឈប់ការរើសអើងចំពោះសហជីព។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករ ជន ណៃ និងកម្មករ វុីត នួន គឺមិនធ្វើការទាមទារឱ្យនិយោជកទទួលយកពួកគាត់ចូលការងារដូចដើមវិញទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករ ជុំ គៀវភត្រា បានចូលធ្វើការដំបូងនៅក្នុងក្រុមហ៊ុន នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ ដោយមិនបានចុះកិច្ចសន្យា ជាលាយលក្ខណ៍អក្សរជាមួយនិយោជកទេ។ គាត់ គឺជាកម្មករផ្នែកដេរ ដែលទទួលប្រាក់ឈ្នួលគោលចំនួន ៨០ ដុល្លារអាមេរិក ក្នុងមួយខែ, ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ និងប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ០៧ ដុល្លារអាមេរិក ក្នុងមួយខែ។ និយោជកបានបញ្ឈប់គាត់ពីការងារនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ប្រហែល ៨៖០០ នាទី ឬ ៩៖០០ នាទី ព្រឹក ដោយមិនបានជូនដំណឹងជាមុន ដោយនិយោជកបានហៅកម្មករ ជុំ គៀវភត្រា ទៅប្រាប់លំនៅដ្ឋានរបស់នាយកក្រុមហ៊ុនដែលនៅជិតក្រុមហ៊ុន។
- ភាគីកម្មករនិយោជិតអះអាងថា ការបញ្ឈប់កម្មករ ជុំ គៀវភត្រា ពីការងារ គឺជាការរើសអើងសហជីព។ នៅថ្ងៃដែលនិយោជកបានបញ្ឈប់កម្មករ ជុំ គៀវភត្រា ពីការងារ និយោជកក៏បានបញ្ឈប់កម្មករនិយោជិតចំនួន ០២នាក់ ផ្សេងទៀត ដែលជាបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីព រួមមាន កម្មករ ជន ណៃ ជាប់ជាអនុប្រធានសហជីព និងកម្មករ វុីត នួន ជាប់ជាលេខាធិការសហជីព ផងដែរ។
- ភាគីកម្មករនិយោជិតបានបន្ថែមទៀតថា នៅថ្ងៃបញ្ឈប់នោះ និយោជកបាននិយាយទៅកាន់កម្មករ ជុំ គៀវភត្រា ថា *"ក្រុមហ៊ុន មិនចង់ឱ្យមានសហជីពនៅក្នុងក្រុមហ៊ុនទេ"*។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ការបញ្ឈប់នេះ មិនត្រឹមត្រូវទេ ព្រោះ កម្មករ ជុំ គៀវភត្រា ពុំធ្លាប់បានប្រព្រឹត្តកំហុស ណាមួយដែលនាំឱ្យឈានដល់ការបញ្ឈប់ពីការងារឡើយ ហើយគាត់ពុំដែលទទួលការព្រមានជាលាយលក្ខណ៍អក្សរណាមួយពីសំណាក់និយោជកផងដែរ។ ដោយយោងតាមច្បាប់ស្តីពីការងារ និងប្រកាសលេខ ៣០៥ គឺកម្មករ ជុំ គៀវភត្រា ត្រូវទទួលបានការពារពីការបញ្ឈប់ ដូចនេះ និយោជកត្រូវទទួលយកកម្មករ ជុំ គៀវភត្រា ឱ្យចូលធ្វើការវិញ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា និយោជកមិនបានសុំការអនុញ្ញាតពីអធិការការងារ នៅក្នុងការបញ្ឈប់កម្មករ ជុំ គៀវភត្រា ទេ។

**ព័ត៌មានទាក់ទងនឹងការបង្កើតសហជីព**

- នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា សម្ព័ន្ធសហជីពកម្ពុជា បានធ្វើការបោះឆ្នោតបង្កើតសហជីពនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៣ ដែលមានបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពកម្ពុជា រួមមាន

៖ (១) កម្មករ ជុំ តឿភត្រា ជាប់ជាប្រធានសហជីព (២)កម្មករ ជន ណៃ ជាប់ជាអនុប្រធានសហជីព និង (៣)កម្មករ វ៉ុត នួន ជាប់ជាលេខាធិការសហជីព។

- ភាគីកម្មករនិយោជិតបានអះអាងថា នៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៣ សម្ព័ន្ធសហជីពកម្ពុជា បានជូនដំណឹងទៅនិយោជកអំពីបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពកម្ពុជាប្រចាំក្រុមហ៊ុន ដោយមានបុគ្គលិកសន្តិសុខរបស់ក្រុមហ៊ុនយកលិខិតនេះទៅជូននាយកក្រុមហ៊ុនមើល។ បន្ទាប់ពីមើលលិខិតជូនដំណឹងនេះរួច នាយកក្រុមហ៊ុនមិនព្រមទទួលយកលិខិតជូនដំណឹងនេះទេ រួចក៏យកលិខិតជូនដំណឹងនេះមកឱ្យបុគ្គលិកសន្តិសុខរបស់ក្រុមហ៊ុនវិញ ដើម្បីឱ្យបុគ្គលិកសន្តិសុខរបស់ក្រុមហ៊ុនប្រគល់ឱ្យសម្ព័ន្ធសហជីពកម្ពុជាវិញ។ ហេតុនេះ សម្ព័ន្ធសហជីពកម្ពុជា បានជូនដំណឹងទៅនិយោជកអំពីបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពកម្ពុជា ប្រចាំក្រុមហ៊ុន ម៉ីង យ៉ា ហ្គាមេន តាមរយៈប្រៃសណីយ៍ ដោយក្រុមហ៊ុន អ៊ី អឹម អេស (EMS) ប៉ុន្តែភាគី កម្មករនិយោជិតមិនបានចាំអំពីកាលបរិច្ឆេទទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យភាគីកម្មករ និយោជិតដាក់ឯកសារ ដែលទាក់ទងនឹងព័ត៌មានទាំងនោះ យ៉ាងយូរត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤។
- នៅថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៤ ភាគីកម្មករនិយោជិតបានដាក់ឯកសារពាក់ព័ន្ធនឹងព័ត៌មានខាងលើ គឺសាលាកប័ត្រផ្ញើ ទៅនិយោជក ស្តីពីជូនដំណឹងអំពីបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំ សហជីពកម្ពុជា ប្រចាំក្រុមហ៊ុន ម៉ីង យ៉ា ហ្គាមេន ដោយក្រុមហ៊ុន អ៊ី អឹម អេស (EMS) ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានបញ្ជាក់ពីកាលបរិច្ឆេទនៃការផ្ញើ គឺនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ១៦៖០០ នាទីរសៀល។
- សហជីពកម្ពុជា ប្រចាំក្រុមហ៊ុន ម៉ីង យ៉ា ហ្គាមេន បានទទួលបង្កាន់ដៃស្នើសុំចុះបញ្ជិកាសហជីព នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ដោយនាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅថ្ងៃសវនាការ ភាគីនិយោជកមិនមានវត្តមានទៅតាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ដូច្នេះ មុននឹងធ្វើការបកស្រាយលើចំណុចវិវាទនៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើអាជ្ញាកណ្តាលអាចធ្វើសវនាការដោយអវត្តមានភាគីនិយោជក ដែរ ឬទេ?

ប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា “*ក្នុងករណីភាគីណាមួយ បានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់* ”។

ទាក់ទងនឹងខ្លឹមសារនៃប្រការ ២១ នៃប្រកាសលេខ ០៩៩ ខាងលើនេះ នៅក្នុងសំណុំរឿងមុនៗ នៅពេលដែលភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវ តែបែរជាខកខានមិនបានបង្ហាញខ្លួននៅ ចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបន្តដំណើរការរបស់ខ្លួន

ដោយធ្វើការបើកសវនាការកំបាំងមុខភាគីដែលអវត្តមាននោះ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ៥៣/០៤ -គួង ហុង, លេខ ៦៣/០៤-សាញូ វីល, លេខ ១៤៨/០៧-ប៉ាយ ហី លេខ ៥៩/០៩-ឃីង ឡៃន, លេខ ១៧៣/១១-ជិន អ៊ីង, លេខ ១៤២/១២-អប្សរា និងលេខ ១០៩/១៣-វិទ្យាស្ថាន ប៊ុណ្ណា កម្ពុជា*)។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជក និងភាគីកម្មករនិយោជិត បានទទួលការអញ្ជើញត្រឹមត្រូវឱ្យចូលរួមសវនាការពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែ នៅថ្ងៃសវនាការមានតែភាគីកម្មករនិយោជិតទេដែលបានចូលរួមសវនាការតាមការអញ្ជើញ។ ចំណែកឯភាគីនិយោជកមិនបានចូលរួមសវនាការតាមការអញ្ជើញទេ ហើយភាគីនិយោជកក៏ពុំមានបញ្ជាក់មូលហេតុត្រឹមត្រូវក្នុងការមិនចូលរួមសវនាការនោះដែរ គឺគ្រាន់តែឱ្យសន្តិសុខក្រុមហ៊ុនទទួលយកលិខិតអញ្ជើញពីមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលតែប៉ុណ្ណោះ ដោយមិនព្រមចុះហត្ថលេខាលើលិខិតអញ្ជើញនេះទេ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ដោយបើកសវនាការអវត្តមានភាគីនិយោជក។

**ចំណុចវិវាទ ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយក កម្មករ ជុំ តឿភត្រា ឱ្យចូលបម្រើការងារដូចដើមវិញ និងបញ្ឈប់ការរើសអើងចំពោះសហជីព**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោម ៖

**(ក) តើនិយោជកមានកាតព្វកិច្ចទទួលយកកម្មករ ជុំ តឿភត្រា ដែលជាបេក្ខជនជាប់ឆ្នោតថ្នាក់ដឹកនាំសហជីពឱ្យចូលធ្វើការវិញ ដែរ ឬទេ?**

មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារចែងថា៖ *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួនអាចធ្វើទៅបាន លុះត្រាណាតែមានការយល់ព្រមពីអធិការការងារ ។..."*

ផ្អែកលើខ្លឹមសារនៃមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថារាល់ការបញ្ឈប់កម្មករនិយោជិតដែលទទួលបានការការពារ និយោជកត្រូវមានការអនុញ្ញាតពីអធិការការងារ និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១៤៩/០៨-ខេមបូ ហាន់ស៊ែ ហេតុផលចំណុចវិវាទទី ១ និងលេខ ១៧៥/០៩-អាជ្ញាធរអប្សរា ហេតុផលចំណុចវិវាទទី២*)។

កថាខណ្ឌទី៣ នៃប្រការ៣ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា ៖ *"កម្មករនិយោជិតទាំងអស់ ដែលជាបក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពទទួលបាននូវការការពារចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ។ ការការពារនេះ មានរយៈពេល ៤៥ ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ ថ្ងៃក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនត្រូវបានជាប់ឆ្នោត។ សហជីពត្រូវជូនដំណឹងទៅនិយោជកអំពីបេក្ខភាពនេះ តាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ។ និយោជកត្រូវអនុវត្តបទប្បញ្ញត្តិនេះ នៅរាល់ពេលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព"*។

យោងតាមប្រការ ៣ កថាខណ្ឌទី៣ នៃប្រកាសលេខ ៣០៥ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការការពារពីការបញ្ឈប់ពីការងារ គឺត្រូវបានផ្ដល់ជូនដល់បេក្ខជនឈរឈ្មោះបោះឆ្នោតថ្នាក់ដឹកនាំសហជីពទាំងអស់ ហើយដែលការការពារនេះមានរយៈពេល ៤៥ ថ្ងៃ មុនការបោះឆ្នោត។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល *លេខ ២៣៩/១៣-មេរីឌាន អ៊ីនដាស្ទ្រី ហ្គាមេន ខេមបូឌា និងលេខ ២៤៧/១៣-បឌី ឃើដ ហ្វេសិន វ៉ែរ ខូអិលធីឌី*)។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងលេខ ៤០/១០-ម៉េង យ៉ាន់ បានបកស្រាយ កថាខណ្ឌទី៣ នៃប្រការ ៣ នៃប្រកាសលេខ ៣០៥ ខាងលើថា ៖ “*នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសំគាល់ឃើញថា ការការពារចំពោះបេក្ខជនដែលជាប់ឆ្នោតនេះមិនអាចបន្តបានរហូតទេ ការការពារគួរតែទទួលបានយ៉ាងហោចណាស់ចំនួន ៤៥ ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ឬអាចបន្តក្នុងរយៈពេលមួយសមរម្យ ដូចជាបន្តការពាររហូតដល់ថ្ងៃ ដែលពួកគាត់ដាក់ពាក្យសុំចុះបញ្ជិកាសហជីព”។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល លេខ ៤០/១០-ម៉េង យ៉ាន់, លេខ ១០៧/ ១២-ស៊ីប៊ីយ៉ា ហេតុផលចំណុចវិវាទទី១ និង២, លេខ ១៩១/១២-អា លឹម, និង លេខ ២៤៧/១៣-បឌី ឃើដ ហ្វេសិន វ៉ែរ ខូអិលធីឌី ហេតុផលចំណុចវិវាទទី២)*។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ យល់ស្របនឹងក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងលេខ ៤០/១០-ម៉េង យ៉ាន់ ដែលថា បេក្ខជនជាប់ឆ្នោតថ្នាក់ដឹកនាំសហជីពទទួលបានការការពារពីការបញ្ឈប់ពីការងារ ចាប់តាំងពីថ្ងៃដែលគាត់បានជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពមកម្លេះ។

នៅក្នុងសេចក្ដីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយថា ដើម្បីទទួលបានការការពារពិសេសកម្មករនិយោជិត ត្រូវបំពេញលក្ខខណ្ឌចំនួន ៣ ដែលរួមមាន *(១) កម្មករនិយោជិត គឺជាកម្មករនិយោជិត ដែលទទួលបាននូវការការពារពិសេស (២) ការបញ្ឈប់ពីការងារស្ថិតនៅក្នុងពេលដែលពួកគេបានទទួលនូវការការពារ និង (៣) កម្មករនិយោជិតត្រូវជូនដំណឹងដល់និយោជកអំពីឈ្មោះអ្នកដែលត្រូវទទួលការការពារ តាមគ្រប់មធ្យោបាយដែលទុកជាបានការ។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៥០/០៥-ហ្វូរចូន ហេតុផលចំណុចវិវាទទី១, លេខ ៦៤/០៥-ជាន វ៉ៃ ហេតុផលចំណុចវិវាទទី១, លេខ ០៧/០៦-ដាយ យ៉ាំង ហេតុផលចំណុចវិវាទទី១, លេខ ០៩/០៦-ប្រ៊ែនដឺ ដាយអឹមិន ស៊ីធី ហេតុផលចំណុចវិវាទទី១ , លេខ ១៤៨/០៧-ប៉ាយ ហ៊ី, លេខ ១៩១/១២-អា លឹម និង លេខ ២៤៧/១៣-បឌី ឃើដ ហ្វេសិន វ៉ែរ ខូអិលធីឌី ហេតុផលចំណុចវិវាទទី២)*។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗដែរ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបន្តពិចារណាថា តើកម្មករ ជុំ គៀភត្រា បានបំពេញនូវលក្ខខណ្ឌទាំងបីខាងលើដែរ ឬទេ?

**១. កម្មករនិយោជិត គឺជាកម្មករនិយោជិតដែលទទួលបាននូវការការពារពិសេស**

តាមរយៈអង្គហេតុ សហជីពកម្ពុជា បានបោះឆ្នោតបង្កើតសហជីព នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៣ ដែលលទ្ធផលនៃការបោះឆ្នោតនេះ គឺកម្មករ ជុំ គៀភត្រា ជាប់ជាប្រធានសហជីពកម្ពុជានៃក្រុមហ៊ុន ម៉ឹងយ៉ា ហ្គាមេន។ ដោយហេតុថា កម្មករ ជុំ គៀភត្រា ជាបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពកម្ពុជា ដូចនេះ តាមរយៈការបក

ស្រាយនៃប្រការ ៣ នៃប្រកាសលេខ ៣០៥ ខាងលើ គាត់ត្រូវទទួលបាននូវការការពារពិសេស។ ដូច្នេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**២. ការបញ្ឈប់ពីការងារស្ថិតនៅក្នុងពេល ដែលគាត់បានទទួលនូវការការពារ**

តាមរយៈអង្គហេតុ និយោជកបានបញ្ឈប់កម្មករ ជុំ តឿភត្រា ពីការងារ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣ ហើយសហជីពនេះបានបោះឆ្នោតនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៣។ ស្របតាមសំណុំរឿងលេខ ៤០/១០-ម៉េង យ៉ាន់ ដែលធ្វើការបកស្រាយខាងលើ គឺបេក្ខជនជាប់ឆ្នោតថ្នាក់ដឹកនាំសហជីព ទទួលបានការការពារពីការបញ្ឈប់ពីការងារ ចាប់តាំងពីថ្ងៃដែលគាត់បានការជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពមកម្ល៉េះ។ នៅក្នុងករណីនេះ កម្មករ ជុំ តឿភត្រា ជាបេក្ខជនជាប់ឆ្នោតជាប្រធានសហជីពកម្ពុជានៃក្រុមហ៊ុន ម៉ឹងយ៉ា ហ្គាមេន ដូចនេះ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**៣. កម្មករនិយោជិតត្រូវជូនដំណឹងដល់និយោជកអំពីឈ្មោះអ្នក ដែលត្រូវទទួលការការពារតាមគ្រប់មធ្យោបាយ ដែលទុកជាបានការ**

ភាគីកម្មករនិយោជិតបានអះអាងថា នៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៣ សម្ព័ន្ធសហជីពកម្ពុជា បានជូនដំណឹងទៅនិយោជកអំពីបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំ សហជីពកម្ពុជា ចំនួន ៣ រូប គឺ ១) កម្មករ ជុំ តឿភត្រា ជាប់ជាប្រធានសហជីព ២) កម្មករ ជន ណៃ ជាប់ជាអនុប្រធានសហជីព និង៣) កម្មករ វ៉ីត នួន ជាប់ជាលេខាធិការសហជីព ដោយបុគ្គលិកសន្តិសុខរបស់ក្រុមហ៊ុនយកលិខិតនេះ ទៅជូននាយកក្រុមហ៊ុនមើល។ បន្ទាប់ពីមើលលិខិតជូនដំណឹងនោះរួច នាយកក្រុមហ៊ុនមិនព្រមទទួលយកលិខិតជូនដំណឹងនេះទេ រួចក៏យកលិខិតជូនដំណឹងនេះមកឱ្យបុគ្គលិកសន្តិសុខរបស់ក្រុមហ៊ុនវិញ ដើម្បីឱ្យបុគ្គលិកសន្តិសុខរបស់ក្រុមហ៊ុន ប្រគល់ឱ្យសម្ព័ន្ធសហជីពកម្ពុជាវិញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះយល់ឃើញថា សម្ព័ន្ធសហជីពកម្ពុជា បានបំពេញកាតព្វកិច្ចជូនដំណឹងដល់និយោជកអំពីបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីព ដែលត្រូវទទួលបានការការពារតាមមធ្យោបាយទុកជាបានការហើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា នាយកក្រុមហ៊ុនបានដឹងអំពីសមាសភាពបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីព ចាប់តាំងពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ មកម្លេះ។ ដូច្នេះ លក្ខខណ្ឌទី៣ បានបំពេញទេ។

សរុបមក កម្មករ ជុំ តឿភត្រា គឺជាប្រភេទកម្មករនិយោជិត ដែលទទួលបានការការពារពិសេស ពីព្រោះថា លក្ខខណ្ឌទាំង ០៣ ត្រូវបានបំពេញ។

ក្នុងសំណុំរឿងនេះ និយោជកមិនបានសុំការអនុញ្ញាតពីអធិការការងារ នៅក្នុងការបញ្ឈប់កម្មករ ជុំ តឿភត្រា ពោលគឺ និយោជកមិនបានគោរពទៅតាមនិតិវិធីនៃការបញ្ឈប់កម្មករនិយោជិត ជាថ្នាក់ដឹកនាំសហជីព ដែលបានទទួលការការពារពិសេសពីការបញ្ឈប់នោះទេ។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ការបញ្ឈប់កម្មករ ជុំ តឿភត្រា មានការរើសអើងសហជីព ព្រោះគាត់ជាថ្នាក់ដឹកនាំសហជីពកម្ពុជា ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាពី ការចោទប្រកាន់របស់ភាគីកម្មករនិយោជិត ទាក់ទងនឹងការរើសអើងសហជីព ដោយភាគីនិយោជកដូចខាងក្រោម ៖

មាត្រា ១២ នៃច្បាប់ស្តីពីការងារចែងថា៖ *“....គ្មាននិយោជកណាម្នាក់ អាចយកបញ្ហា...ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីពដើម្បីជាលេសធ្វើសេចក្តីសំរេចអំពី:... វិន័យ ឬការផ្តាច់កិច្ចសន្យាការងារ...”*។

មាត្រា ២៧៩ នៃច្បាប់ស្តីពីការងារចែងថា៖ *“ត្រូវហាមឃាត់ចំពោះនិយោជកគ្រប់រូប មិនឱ្យយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមក្នុងសកម្មភាពរបស់សហជីពនៃកម្មករនិយោជិត ដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសឱ្យចូលធ្វើការងារ ការដឹកនាំ និងការបែងចែកការងារ ការតំឡើងថ្នាក់ ការផ្តល់ប្រាក់ឈ្នួល និងការផ្តល់ផលប្រយោជន៍វិធានការដាក់វិន័យ និងការបណ្តេញចេញ ”* ។

ទាក់ទងនឹងការកំណត់អំពីការរើសអើងសហជីព ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាង ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ដើម្បីកំណត់ថា មានការរើសអើងសហជីពកើតមានឡើងដែរ ឬទេ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១៧/០៧-ឆាមថិចថាយ ហេតុផលចំណុចវិវាទទី១, លេខ ១៤៨/០៧-ប៉ាយហ៊ឺ, លេខ៣៥/១៣- និចធី អ៊ីភែរីល, និង លេខ ៤១/១៣-គម្រោងកិច្ចសហប្រត្តិបត្តិការឥណ្ឌា ដើម្បីជួសជុលប្រាសាទតាព្រហ្ម ហេតុផលចំណុចវិវាទទី១* )។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ទាក់ទងនឹងបន្ទុកភស្តុតាង និងវិធីសាស្ត្រក្នុងការកំណត់អំពីការរើសអើងផងដែរ។

តាមរយៈអង្គហេតុ ភាគីកម្មករនិយោជិតបានអះអាងថា នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ៨៖០០ នាទី ឬ៩ ៖០០នាទី ព្រឹក និយោជកបានបញ្ឈប់កម្មករ ជុំ តឿភត្រា នៅឯលំនៅដ្ឋានរបស់នាយកក្រុមហ៊ុន ដែលមានទីតាំងក្បែរក្រុមហ៊ុន ដោយបានប្រាប់គាត់ថា *“ក្រុមហ៊ុនមិនចង់ឱ្យមានសហជីពនៅក្នុងក្រុមហ៊ុនទេ”*។ នៅថ្ងៃដដែលនេះ និយោជកក៏បានបញ្ឈប់កម្មករនិយោជិតចំនួន ០២ នាក់ ផ្សេងទៀត ដែលជាបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពកម្ពុជា ប្រចាំក្រុមហ៊ុន គឺកម្មករ ជន ណៃ ជាប់ជាអនុប្រធានសហជីព និងកម្មករ វ៉ុត ទួន ជាប់ជាលេខាធិការសហជីពផងដែរ។ លើសពីនេះទៀត ភាគីកម្មករនិយោជិតបានអះអាងថា កម្មករ ជុំ តឿភត្រា ពុំធ្លាប់បានប្រព្រឹត្តកំហុសណា មួយដែលនាំឱ្យឈានដល់ការបញ្ឈប់ពីការងារឡើយ ហើយគាត់ពុំដែលទទួលការព្រមានជាលាយលក្ខណ៍អក្សរណាមួយពីនិយោជកផងដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងយល់ឃើញថា សម្តីរបស់នាយកក្រុមហ៊ុន និងសកម្មភាពបញ្ឈប់កម្មករ ជុំ តឿភត្រា និងបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំ ០២ នាក់ ទៀតក្នុងថ្ងៃតែមួយ គឺបញ្ជាក់ពីចេតនាមិនចង់ឱ្យកម្មករ ជុំ តឿភត្រា និងបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំ បង្កើតសហជីពនៅក្នុងក្រុមហ៊ុនទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងនេះយល់ឃើញថា ភាគីកម្មករនិយោជិតបានបង្ហាញពីអង្គហេតុគ្រប់គ្រាន់ទាក់ទងនឹងការរើសអើងសហជីព។ ពោល គឺ ព្រឹត្តិការណ៍នៃការបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំង ០៣ នាក់ ក្រោយពីការបោះឆ្នោតបង្កើតសហជីព។ ដោយសារតែភាគីនិយោជកអវត្តមាននៅក្នុងថ្ងៃសវនាការ ដូច្នេះ ភាគីនិយោជកបានបោះបង់ឱកាសនៅក្នុងការឆ្លើយតប ទៅនឹងការចោទប្រកាន់របស់ភាគីកម្មករនិយោជិត ក៏ដូចជាខកខាន ក្នុងការបង្ហាញភស្តុតាង ឬអង្គហេតុផ្ទុយទាំងឡាយ ដើម្បីដោះបន្ទុកពីការចោទប្រកាន់ទាក់ទងនឹងការរើសអើងសហជីពនេះ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការបញ្ឈប់ថ្នាក់ដឹកនាំសហជីព ជុំ តឿភត្រា គឺមានពាក់ព័ន្ធនឹងការរើសអើងសហជីព។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកទទួលយកកម្មករ ជុំ គៀកត្រា ឱ្យចូលធ្វើការដូចដើមវិញ និងបញ្ឈប់ការរើសអើងចំពោះសហជីព។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ១ ៖** បង្គាប់ឱ្យនិយោជកទទួលយកកម្មករ ជុំ គៀកត្រា ឱ្យចូលធ្វើការដូចដើមវិញ និងបញ្ឈប់ការរើសអើងចំពោះសហជីព។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **យូ សួនធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណន**

ហត្ថលេខា ៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ------------------------------